FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៤ លេខ ៣៥ ខែមេសា ឆ្នាំ ២០០៥

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

A Publication of the Cambodian Agricultural Research and Development Institute



# បច្ចេកទេសដាំដុះដំណាំសណ្តែកសៀង



ដំណាំសណ្តែកសៀង មានសារសំខាន់បំផុតសំរាប់មនុស្ស និងសត្វ ដោយគេយកវាមកកែច្នៃធ្វើជាអាហារបានច្រើនប្រភេទដូចជា សៀង ទឹកស៊ីអ៊ីវ ទឹកសណ្តែក តៅហ៊ូ ពពុះសណ្តែក និងអាហារផ្សេងៗ។ ក្រៅពីនោះផលិតផលសណ្តែកសៀង គេអាចទទួលបានជាប្រេងសណ្តែក និង ម្សៅ ដោយប្រេងសណ្តែកយកមកធ្វើជាអាហារមនុស្ស មិនតែប៉ុណ្ណោះគេអាចបញ្ចូលទៅក្នុងរោងចក្រធ្វើជាសាប៊ូបានទៀតផង។ ដើមសណ្តែកសៀង អាចយកមកធ្វើជាចំណីសត្វពាហនៈ ហើយក៏អាចយកមកប្រើប្រាស់ក្នុងការកែលំអរគុណភាពដី។

ដំណាំនេះត្រូវបាននាំចូលមកដាំនៅប្រទេសកម្ពុជា នៅឆ្នាំ១៩០០ ហើយបានដាំនៅតាមមាត់ច្រាំងទន្លេមេគង្គ បន្ទាប់មកបានរីកសាយភាយនៅភូមិភាគដីខ្ពស់ ហើយបានក្លាយជាដំណាំប្រចាំឆ្នាំមួយយ៉ាងសំខាន់បំផុតនៅតាមខ្ពង់រាបដីក្រហមឡាបានសៀក ខេត្តកំពង់ចាម។ ក្រៅពីនេះគេឃើញមានដាំនៅខេត្តបាត់ដំបង ប៉ៃលិន កំពង់ធំ រតនគីរី និងបន្ទាយមានជ័យ ។ល។ តាមស្ថិតិកសិកម្ម បានបង្ហាញអោយឃើញថានៅឆ្នាំ ២០០៣ - ២០០៤ នេះដំណាំសណ្តែកសៀង បានដាំច្រើនជាងគេបង្អស់នៅខេត្តកំពង់ចាមមានរហូតដល់ ២៨.៨៩៨ហិកតា ដែលទទួលបានទិន្នផលជាមធ្យម ០.៩១តោន ក្នុងមួយហិកតា។ បន្ទាប់មកនៅ ខេត្តបាត់ដំបង ដែលដាំដុះលើផ្ទៃដី ១២.៥៤៩ហិកតា និងទទួលបានទិន្នផលជាមធ្យមរហូតដល់ ១.៨៦៣តោន ក្នុងមួយហិកតា។

## ក្នុងព្រឹត្តិប័ត្រលេខនេះយើងលើកយកនូវបច្ចេកទេសដាំដុះដំណាំសណ្តែកសៀងមកធ្វើការបង្ហាញ

### ១. ពេលវេលានៃការដាំដុះ

ដំណាំសណ្តែកសៀង ជាដំណាំដែលទាមទារនូវរដូវកាលដាំដុះយ៉ាងត្រឹមត្រូវបំផុតហើយតំបន់និមួយៗ តែងតែកំណត់រយៈពេលដាំដុះខុសៗគ្នា ព្រោះអាស្រ័យទៅតាមអាកាសធាតុនៃតំបន់នោះ។ នៅតំបន់ខ្ពង់រាបប្រទេសកម្ពុជា កសិករធ្វើការដាំដុះដំណាំសណ្តែកសៀងបានតែមួយលើកប៉ុណ្ណោះក្នុងមួយឆ្នាំ គឺនៅក្នុងកំឡុងដើមខែកក្កដា។ ចំណែកនៅតាមតំបន់មាត់ទន្លេមេគង្គ កសិករអាចធ្វើការដាំដុះបាន ២លើក ដោយលើកទី១ នៅចុងខែមិនា ដល់ដើមខែមេសា និងលើកទី២ ចាប់ផ្តើមនៅចុងខែតុលា ដល់ដើមខែវិច្ឆិកា។



### ២. ការរៀបចំដី និងការបង្កើនជីជាតិដី

ដំណាំសណ្តែកសៀង ក៏ដូចជាដំណាំដទៃទៀតដែរវាត្រូវការដីដែលមានលក្ខណៈស្អាតល្អ មានខ្យល់ចេញចូលគ្រប់គ្រាន់ និងដីមិនជាំទឹក។ ការភ្ជួររាស់ដីគេមិនកំណត់ជំរៅទូទៅបានទេ គឺអាស្រ័យទៅតាមតំបន់ ដោយតំបន់ខ្លះគេអាចភ្ជួរជំរៅ ៣០ស.ម និងនៅតំបន់ខ្លះទៀតគេភ្ជួរត្រឹមតែ ២០ស.ម ប៉ុណ្ណោះ។ ការភ្ជួរដោយប្រើកំលាំងអូសទាញ គឺមានជំរៅរាក់តែត្រូវធ្វើយ៉ាងណាអោយបានជំរៅពី ១៥-២០ស.ម ទើបជាការល្អ។ ការរៀបចំដីជាទូទៅគេច្រើនធ្វើចំនួន ២-៣ដង មុនពេលដាំដើម្បីអោយដីធូរល្អ និងដើម្បីសំលាប់ស្មៅចង្រៃ។ ចំពោះដីមិនមានជីជាតិដើម្បីបង្កើនទិន្នផល គេត្រូវប្រើជីគីមីលាយជាមួយជីសរីរាង្គ ដោយយើងត្រូវដឹងថាចាប់ពីពេលដំណុះរហូតដល់ចាប់ផ្តើមផ្កា សណ្តែកសៀងត្រូវការសារធាតុចិញ្ចឹមតិច តែចាប់ពីពេលចេញផ្ការហូតដល់ដំណាក់កាលបង្កើតគ្រាប់ សណ្តែកសៀងត្រូវការសារធាតុចិញ្ចឹមច្រើន ហើយសេចក្តីត្រូវការនេះថយចុះនៅចុងបញ្ចប់នៃវគ្គបង្កើតផ្លែ។



## ៣. ការជ្រើសរើសពូជ និងការរៀបចំគ្រាប់មុនដាំ

ការជ្រើសរើសពូជជាកត្តាមួយយ៉ាងសំខាន់ដែលធ្វើអោយមានការប៉ះពាល់ដល់ទិន្នផល ដូចនេះយើងត្រូវធ្វើការជ្រើសរើសពូជអោយបានល្អ ដោយអនុវត្តតាមលក្ខណៈបច្ចេកទេស។ ពេលប្រមូលផលត្រូវធ្វើការជ្រើសរើសនូវពូជណាដែលមានផ្លែច្រើនក្នុងមួយដើមដោយមានចំនួន ២-៧គ្រាប់ ក្នុងមួយផ្លែ ដោយពុំសូវមានគ្រាប់ស្វិត ហើយគ្រាប់ត្រូវមានលក្ខណៈស្អួតល្អគ្មានជំងឺ សត្វល្អិតបំផ្លាញដំណុះលើសពី ៨៥ភាគរយ។ ត្រូវធ្វើការសំអាតគ្រាប់ពូជអោយស្អាត ហើយយកទៅដាក់ហាលថ្ងៃស្រទន់ ៣-៤ម៉ោង លើកន្ទេលមុនធ្វើការដាំដុះមួយថ្ងៃ ឬយកទៅប្រឡាក់ថ្នាំ TMTD ៣-៤គីឡូក្រាម ក្នុងមួយតោនគ្រាប់ ឬ Fentiourum ពី ៣-៤គីឡូក្រាម ក្នុងមួយតោនគ្រាប់ ការអនុវត្តបែបនេះដើម្បីជៀសផុតពីជំងឺផ្សេងៗ។

## ៤. វិធីសាស្ត្រដាំដុះ

ការដាំដុះដំណាំសណ្តែកសៀង គេអាចអនុវត្តបានច្រើនរបៀបផ្សេងៗគ្នាដោយអាស្រ័យទៅតាមតំបន់និមួយៗដូចជា ដាំតាមរបៀបព្រួស ដាំដោយរោយគ្រាប់ជាជួរ (ឆូតជួរដោយប្រើត្រាក់ទ័រ ឬនង្គ័ល) និងការដាំដោយកាប់រណ្តៅ ដូច្នេះក៏រិតគ្រាប់ដែលប្រើប្រាស់សំរាប់ដាំក៏មិនដូចគ្នាដែរ។ ប្រសិនបើដាំដោយប្រើម៉ាស៊ីនគេដាក់ចំនួន ៣-៥គ្រាប់ ក្នុងមួយរណ្តៅ ប្រើប្រាស់គ្រាប់ពូជចំនួន ២៥ ទៅ ៣០គីឡូក្រាម ក្នុងមួយហិកតា។ តែបើដាំដោយប្រើកំលាំងមនុស្សដាក់តាមជួរប្រើគ្រាប់ពូជរហូតដល់ទៅ ៥០ ទៅ ៦០គីឡូក្រាម ក្នុងមួយហិកតា។ ចំណែកការដាំដោយប្រើប្រាស់វិធីសាស្ត្រព្រួស ប្រើប្រាស់គ្រាប់ពូជរហូតដល់ទៅ ៥០គីឡូក្រាម ក្នុងមួយហិកតា។ ដើម្បីទទួលបាននូវទិន្នផលខ្ពស់ ហើយងាយស្រួលក្នុងការត្រួតពិនិត្យសត្វល្អិត និងជំងឺ ដង់ស៊ីតែដែលល្អគឺមិនត្រូវអោយលើសពី ៦៦ ០០០គុម្ព ក្នុងមួយហិកតា និងជំរៅគ្រាប់ ២-៥ស.ម។ ជាទូទៅគេប្រើចន្លោះគុម្ព ៥០ ស.ម x ៣០ស.ម។

## ៥. ការប្រើប្រាស់ជី

ការប្រើប្រាស់ជីលើដំណាំសណ្តែកសៀងគឺអាស្រ័យទៅតាមប្រភេទដី។ ចំពោះដីខ្សាច់ (ដីព្រៃខ្មែរ ដីប្រទះឡាង) ប្រើប្រាស់ជីអ៊ុយរ៉េ ១២៤គ.ក ជី DAP ៩៥គ.ក និងជី KCl៣៧គ.ក ក្នុងមួយហិកតា។ ចំណែកដីល្បាប់ ឬឥដ្ឋ (ដីកំពង់សៀម ដីឡាបានសៀក ដីទួលសំរោង ដីកៀនស្វាយ) ប្រើប្រាស់ជីអ៊ុយរ៉េ ១៧៤គ.ក ជី DAP ១០៧គ.ក និងជី KCl ៤៥គ.ក ក្នុងមួយហិកតា។ ដោយប្រើប្រាស់ ១០០ភាគរយនៃ P និង ៥០ភាគរយ នៃ N,K សំរាប់ទ្រាប់បាតពេលដាំ ចំណែក N,K ដែលនៅសល់ ៥០ភាគរយ ទៀតសំរាប់បំប៉នពេលសណ្តែកសៀងមានអាយុ ៣-៤ សប្តាហ៍ *(ការិយាល័យវិទ្យាសាស្ត្រដី និង ទឹក ២០០៤)*។

## ៦. ការថែទាំ និងការកំចាត់ស្មៅ

ការកំចាត់ស្មៅ ត្រូវធ្វើឡើងចំនួន៣លើក: លើកទី១ នៅពេលដែលសណ្តែកសៀងមានអាយុ ១៥-២០ថ្ងៃ។ លើកទី២ នៅពេលដែលសណ្តែកសៀងមានអាយុ ៥៥-៦០ថ្ងៃ បន្ទាប់ពីដុះពន្លក ដោយពូនគល់តែម្តង និងលើកទី៣ ដោយគ្រាន់តែដើរដកឬស ឬកាត់ដើមស្មៅដែលមានការដុះលូតលាស់នៅក្នុងជួរសណ្តែកសៀងចេញតែប៉ុណ្ណោះ។ ត្រូវចុះត្រួតពិនិត្យតាមដានជាប់ជាប្រចាំដើម្បីការពារនូវបញ្ហាផ្សេងៗដែលកើតមានឡើង។

## ៧. ជំងឺ និងសត្វល្អិតចង្រៃ

- **ជំងឺ :** ជំងឺដែលជួបប្រទះលើដំណាំសណ្តែកសៀងមានៈ ជំងឺ Fusarium (បង្កដោយផ្សិត Fusarium Linle), ជំងឺ Ascochyta (បង្កដោយផ្សិត Ascochyta Sojaecola Abramov), ជំងឺ Mosaic (បង្កដោយផ្សិត Yellow Modaic Vurus ឬ Phaseolus Vurus), ជំងឺ Selerotinia, ជំងឺស្វិតឬស, ជំងឺរលួយឬស ឬ គល់ស្អុយ, ជំងឺច្រេះដែក និងជំងឺស្រពោនដើម (បង្កដោយបាក់តេរី Pseudomonas Solanacearum) ។ល។
- **សត្វល្អិតចង្រៃ :** សត្វល្អិតដែលជួបប្រទះលើដំណាំសណ្តែកសៀងមានៈ ពីងពាងលឿង, ពីងពាងក្រហម, សង្កើចបៃតង, និងដង្កូវរុយ ។ល។

## ៨. ការប្រមូលផល



ត្រូវធ្វើការប្រមូលផលនៅពេលដែលស្លឹកចាស់ជ្រុះអស់ បើពន្យាពេលប្រមូលផលពី ១៥-២០ថ្ងៃ ក្រោយពេលទុំនោះទិន្នផលអាចថយចុះពី ១៥-២០ភាគរយ។ ច្រូតដើមសណ្តែកសៀងយកមកហាលថ្ងៃចំនួនមួយព្រឹក រួចដល់ពេលរសៀលទើបយកទៅបោកបែនយកគ្រាប់ ដោយធ្វើយ៉ាងណាសំអាតអោយបានស្អាតល្អរួចសំដិលហាលថ្ងៃក្តៅល្មមរយៈពេល ៣-៥ថ្ងៃ ច្រកថង់ ឬបាវទុកដាក់នៅត្រង់កន្លែងស្ងួតដែលមានខ្យល់ចេញចូលល្អ។

សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យក្សេត្រវិទ្យា និងប្រព័ន្ធកសិកម្ម មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ.

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ ទូរអក្ខរ: cardi@cardi.org.kh វែបសាយ: www.cardi.org.kh

SPheav@cardi.org.kh CPhaloeun@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh